**ព្រះរាជាណាចក្រកម្ពុជា**
**ជាតិ សាសនា ព្រះមហាក្សត្រ**

MINISTRY OF ECONOMY AND FINANCE

ក្រសួងសេដ្ឋកិច្ច និង ហិរញ្ញវត្ថុ　　　　ទីស្ដីការគណៈរដ្ឋមន្ត្រី　　　　ក្រសួងទេសចរណ៍

លេខ ១៥៤៦ សហវ.ប្រក

# ប្រកាសអន្តរក្រសួង
## ស្ដីពី
## ការចេញ-ចូល តំបន់រមណីយដ្ឋានអង្គរដោយឥតបង់ថ្លៃ

**ឧបនាយករដ្ឋមន្ត្រី រដ្ឋមន្ត្រី ទទួលបន្ទុកទីស្ដីការគណៈរដ្ឋមន្ត្រី**　　**ទេសរដ្ឋមន្ត្រី រដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**　　**រដ្ឋមន្ត្រី ក្រសួងទេសចរណ៍**

- បានឃើញរដ្ឋធម្មនុញ្ញនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៩១៣/៩០៣ ចុះថ្ងៃទី២៤ ខែកញ្ញា ឆ្នាំ២០១៣ ស្ដីពីការតែងតាំងរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០៤១៦/៣៦៨ ចុះថ្ងៃទី០៤ ខែមេសា ឆ្នាំ២០១៦ ស្ដីពីការកែសម្រួល និងបំពេញបន្ថែមសមាសភាពរាជរដ្ឋាភិបាលនៃព្រះរាជាណាចក្រកម្ពុជា
- បានឃើញព្រះរាជក្រមលេខ ០២/នស/៩៤ ចុះថ្ងៃទី២០ ខែកក្កដា ឆ្នាំ១៩៩៤ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការរៀបចំ និងប្រព្រឹត្តទៅនៃគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/០៩ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតទីស្ដីការគណៈរដ្ឋមន្ត្រី
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៨ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- បានឃើញព្រះរាជក្រមលេខ នស/រកម/០១៩៦/១៥ ចុះថ្ងៃទី២៤ ខែមករា ឆ្នាំ១៩៩៦ ដែលប្រកាសឱ្យប្រើច្បាប់ ស្ដីពីការបង្កើតក្រសួងទេសចរណ៍
- បានឃើញព្រះរាជក្រឹត្យលេខ នស/រកត/០២៩៥/១២ ចុះថ្ងៃទី១៩ ខែកុម្ភៈ ឆ្នាំ១៩៩៥ ស្ដីពីការបង្កើតអាជ្ញាធរដើម្បីការពាររមណីយដ្ឋាននិងរៀបចំតំបន់អង្គរ កែសម្រួលដោយព្រះរាជក្រឹត្យលេខ នស/រកត/០១៩៩/១៨ ចុះថ្ងៃទី២២ ខែមករា ឆ្នាំ១៩៩៩



ផ្លូវលេខ ៩២ សង្កាត់វត្តភ្នំ ខណ្ឌដូនពេញ រាជធានីភ្នំពេញ កម្ពុជា
St.92, Sangkat Wat Phnom, khan Daun Penh, Phnom Penh, CAMBODIA.
ទូរស័ព្ទ : ៨៥៥-២៣-៧២៤ ៦៦៤ ទូរសារ : ៨៥៥-២៣-៤២៧ ៧៩៨
Phone : 855-23-724 664 Fax : 855-23-427 798

- យោងចំណារឯកភាពដ៏ខ្ពង់ខ្ពស់របស់សម្តេចតេជោនាយករដ្ឋមន្ត្រី ចុះថ្ងៃទី០២ ខែកញ្ញា ឆ្នាំ២០១៦ លើលិខិតលេខ ៦៩៦៥សហវ ចុះថ្ងៃទី១៨ ខែសីហា ឆ្នាំ២០១៦ របស់ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ និងក្រសួងទេសចរណ៍
- យោងលិខិតលេខ ៩៥៧ សជណ ចុះថ្ងៃទី១២ ខែកញ្ញា ឆ្នាំ២០១៦ របស់ទីស្តីការគណៈរដ្ឋមន្ត្រី

## សម្រេច

**ប្រការ ១.-**

ត្រូវបានអនុញ្ញាតឱ្យ ចេញ-ចូល ក្នុងតំបន់រមណីយដ្ឋានអង្គរឥតបង់ថ្លៃ ដោយអាជ្ញាធរជាតិអប្សរាសម្រាប់÷

១. អ្នកសិក្សាស្រាវជ្រាវ អំពីបុរាណវិទ្យា វប្បធម៌ និងវិស័យនានាពាក់ព័ន្ធនឹងរមណីយដ្ឋានអង្គរ ដែលមានការយល់ព្រមជាមុនពីអាជ្ញាធរជាតិអប្សរា ឬក្រសួងវប្បធម៌ និងវិចិត្រសិល្បៈ។

២. អ្នកបម្រើការងារ ប្រតិភូអន្តរជាតិ និងដៃគូអភិវឌ្ឍន៍នានា ដែលមានកិច្ចសហប្រតិបត្តិការក្នុងកិច្ចការអភិរក្ស ជួសជុលលើកតម្លៃបេតិកភណ្ឌវប្បធម៌ នៅក្នុងរមណីយដ្ឋានអង្គរ ។

**ប្រការ ២.-**

ការអនុញ្ញាតចេញ-ចូល ក្នុងតំបន់រមណីយដ្ឋានអង្គរឥតបង់ថ្លៃដោយអាជ្ញាធរជាតិអប្សរា ត្រូវកំណត់ ដូចខាងក្រោម ÷

១. ការអនុញ្ញាតរយៈពេលខ្លី គឺមានលក្ខណៈជាប្រភេទលិខិតអនុញ្ញាត មានបិទរូបថត ដែលមានរយៈពេលចាប់ពី ០១ថ្ងៃ ដល់ ១០ថ្ងៃ។

២. ការអនុញ្ញាតរយៈពេលវែង គឺមានលក្ខណៈជាប្រភេទប័ណ្ណអនុញ្ញាត មានបិទរូបថត ដែលមានរយៈពេលចាប់ពី ១១ថ្ងៃ ដល់ ០១ឆ្នាំ។

**ប្រការ ៣.-**

គណៈប្រតិភូអន្តរជាតិ ដែលបានមកបំពេញទស្សនកិច្ចផ្លូវការនៅក្នុងព្រះរាជាណាចក្រកម្ពុជា ហើយមានបំណងទស្សនាតំបន់រមណីយដ្ឋានអង្គរ ក្រសួង ស្ថាប័នសាមីពាក់ព័ន្ធ ត្រូវទទួលបន្ទុកចំណាយលើថ្លៃទិញប័ណ្ណទស្សនា។

**ប្រការ ៤.-**

គ្រឹះស្ថានអង្គរត្រូវផ្តល់ព័ត៌មានពីទិន្នន័យប្រតិភូរបស់ក្រសួង ឬស្ថាប័នពាក់ព័ន្ធ ដែលបានចេញ-ចូលតំបន់រមណីយដ្ឋានអង្គរ មកអាជ្ញាធរជាតិអប្សរា ជារៀងរាល់ដំណាច់ខែនីមួយៗ។

**ប្រការ ៥.-**

បទប្បញ្ញត្តិទាំងឡាយណាដែលផ្ទុយនឹងប្រកាសអន្តរក្រសួងនេះ ត្រូវទុកជានិរាករណ៍។

**ប្រការ ៦.-**

ទីស្តីការគណៈរដ្ឋមន្ត្រី ក្រសួងសេដ្ឋកិច្ចនិងហិរញ្ញវត្ថុ ក្រសួងទេសចរណ៍ គ្រប់ក្រសួង ស្ថាប័នពាក់ព័ន្ធ សាលារាជធានី ខេត្ត អាជ្ញាធរជាតិអប្សរា គ្រឹះស្ថានអង្គរ ត្រូវទទួលបន្ទុកអនុវត្តប្រកាសអន្តរក្រសួងនេះ ឱ្យមានប្រសិទ្ធភាពចាប់ពីថ្ងៃទី០១ ខែមករា ឆ្នាំ២០១៧ តទៅ។

ធ្វើនៅរាជធានីភ្នំពេញ,ថ្ងៃទី២៧ខែធ្នូ ឆ្នាំ២០១៦

**ឧបនាយករដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីទទួលបន្ទុកទីស្តីការគណៈរដ្ឋមន្ត្រី**

សុខ-អាន

**ទេសរដ្ឋមន្ត្រី**
**រដ្ឋមន្ត្រីក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ**

**បណ្ឌិត. អូន ព័ន្ធមុនីរ័ត្ន**

**រដ្ឋមន្ត្រី**
**ក្រសួងទេសចរណ៍**

**ថោង ខុន**

**កន្លែងទទួល៖**

- ទីស្តីការគណៈរដ្ឋមន្ត្រី
- ក្រសួងសេដ្ឋកិច្ច និងហិរញ្ញវត្ថុ
- ក្រសួងទេសចរណ៍
- អគ្គលេខាធិការរាជរដ្ឋាភិបាល
- ខុទ្ទកាល័យសម្តេចអគ្គមហាសេនាបតីតេជោ នាយករដ្ឋមន្ត្រី
- ខុទ្ទកាល័យ សម្តេច ឯកឧត្តម លោកជំទាវ ឧបនាយករដ្ឋមន្ត្រី
- ដូចប្រការ៦
- រាជកិច្ច
- ឯកសារ-កាលប្បវត្តិ



42